**ប្រមុខរដ្ឋស្តីទី**

*រាល.០៤.០៨.១៤០*

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខ: ១៤២ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ ចាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/១៩០

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

តែងតាំងជាទីប្រឹក្សា នាយកនិងនាយករងខុទ្ទកាល័យ និងជំនួយការឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **អ៊ិន ម៉ុយ** ជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២- ឯកឧត្តម **អុម ស៊ីសាវដា** ជាទីប្រឹក្សាឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៣- ឯកឧត្តម **ហែម ហេង** ជាទីប្រឹក្សា និងជានាយករងខុទ្ទកាល័យឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៤- ឯកឧត្តម **ទ័រន់ ឌល** ជាទីប្រឹក្សាឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៥- ឯកឧត្តម **លុយ ដារ៉ាត** ជាជំនួយការឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយក

**មាត្រា ២.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០០៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

*ចរ/ល.០៤.០៨.១៩១*

លេខៈ ៦៤៣ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាខី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/១៧១

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

តែងតាំងជាទីប្រឹក្សា នាយកនិងនាយករងខុទ្ទកាល័យ និងជំនួយការ ឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១ឯកឧត្តម | **ចំនួ នរ៉ា** | ជាទីប្រឹក្សាឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី | មានឋានៈស្មើរដ្ឋលេខាធិការ |
| ២ឯកឧត្តម | **ស្រី ចន្ទី** | ជាទីប្រឹក្សាឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី | មានឋានៈស្មើរដ្ឋលេខាធិការ |
| ៣ឯកឧត្តម | **អែម រេត** | ជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តម **ញឹក ប៊ុនឆៃ**ឧបនាយករដ្ឋមន្ត្រី | មានឋានៈស្មើអនុរដ្ឋលេខាធិការ |
| ៤ឯកឧត្តម | **ហុង ឡុង** | ជាទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ ឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី | មានឋានៈស្មើអនុរដ្ឋលេខាធិការ |

៥- ឯកឧត្តម **ទៀន មាន** ជាជំនួយការឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយក

**មាត្រា ២.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

៣៧ស.០៤.០៨.១៨២

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខៈ ១៤៤ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ៨ ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាងី តាន់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៨១/០០៤ /២០០៤

ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៤

**សេចក្តីសំរេច**

លេខ : ០៥៩/០០១/២០០៤ កបធ.ច

ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤

**ក្រុមប្រឹក្សាធម្មនុញ្ញ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ១០៧ រស ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៤ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៤

**ក្រោយពីបានស្តាប់របាយការណ៍សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដោយប្រធានរដ្ឋសភាស្តីទី ជាការស្របនឹងរដ្ឋធម្មនុញ្ញ ( ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ )

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ជាភារកិច្ចរបស់ក្រុមប្រឹក្សា-ធម្មនុញ្ញ ( ឃ្លាទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ )

-យល់ឃើញថា នៅក្នុងគ្រប់ជំពូក និងប្រការទាំងអស់នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ពុំមានបទបញ្ញត្តិណា ដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ លើកលែងតែបទបញ្ញត្តិនៃប្រការ ៥១ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ស្តីពី

ការជ្រើសតាំងប្រធានបណ្តោះអាសន្នមួយរូបឱ្យដឹកនាំការប្រជុំ ។ បទបញ្ញត្តិនេះ ជាប្រការមួយមានការលំបាកក្នុងការអនុវត្តន៍ជាក់ស្តែង ហើយមិនស្របនឹងមាត្រា ៨៧ ថ្មីនៃរដ្ឋធម្មនុញ្ញ ។

**សំរេច**

**មាត្រា ១.-** បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មាន ១៧ ជំពូក និង ៨៣ ប្រការ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៤ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែប្រការ ៥១ ដែលមិនស្របនឹងមាត្រា ៨៧ ថ្មីនៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ប៊ិន ឈិន

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ......អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរក្របខណ្ឌមន្ត្រីរាជការស៊ីវិល រវាង
## អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
## និងយុវនីតិសម្បទា អតីតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន
## ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការ ជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០០៤

## សំរេច

**មាត្រា១ :** ត្រូវបានផ្ទេរក្របខណ្ឌមន្ត្រីរាជការស៊ីវិលចំនួន ៥៥៦ នាក់ ( ដូចមានក្នុងឧបសម្ព័នជូនភ្ជាប់ ) របស់អគ្គនាយកដ្ឋានការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រែកព្នៅ មជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ (ពូនភ្នំ ) មន្ទីរសង្គមកិច្ចការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង ដែលបំរើការងារវិស័យការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្នែកការងាររដ្ឋបាល និងហិរញ្ញវត្ថុ នៃអតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា អោយមកបំរើ ការងារនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា២ :** ត្រូវបានផ្ទេរក្របខណ្ឌមន្ត្រីរាជការស៊ីវិលចំនួន ៦៤ នាក់ (ដូចមានក្នុងឧបសម្ព័ន្ធជូនភ្ជាប់) របស់នាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងអប់រំ យុវជន និងកីឡា អោយមកបំរើការងារនៅក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា៣ :** ត្រូវបានផ្ទេរក្របខណ្ឌមន្ត្រីរាជការស៊ីវិលចំនួន ៤០១ នាក់ (ដូចមានក្នុងឧបសម្ព័ន្ធជូនភ្ជាប់) របស់នាយកដ្ឋានសោធនអតីតយុទ្ធជន នាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន មជ្ឈមណ្ឌលព្យាបាលដោយចលនា និងមន្ទីរកិច្ចការនារី និងអតីតយុទ្ធជនខេត្ត-ក្រុង ដែលបំរើការងារវិស័យអតីតយុទ្ធជន នៃអតីតក្រសួងកិច្ចការនារី និងអតីតយុទ្ធ ជន អោយមកបំរើការងារនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**មាត្រា៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ និងអភិបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូនៈ**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៥

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរ អាគារ ចលនទ្រព្យ អចលនទ្រព្យ និង ឯកសារពាក់ពន្ធ័ រវាង អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះ បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អតីតក្រសួងកិច្ចការនារី និងអតីតយុវជន ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការ ជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០០៤

## សំរេច

**មាត្រា១ :** ត្រូវបានផ្ទេរអាគារ ព្រមទាំងចលនទ្រព្យ អចលនទ្រព្យ និងឯកសារពាក់ពន្ធ័ របស់អគ្គនាយកដ្ឋានការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រែកព្នៅ មជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញ

កម្ពុជា-ថៃ (ពូនភ្នំ ) នៃអតីតក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អោយមក ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា២** : ត្រូវបានផ្ទេរអគារ ព្រមទាំងចលនទ្រព្យ អចលនទ្រព្យ និងឯកសារពាក់ពន្ធ័របស់នាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងអប់រំ យុវជន និងកីឡា អោយមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា៣** : ត្រូវបានផ្ទេរចលនទ្រព្យ និងឯកសារពាក់ព័ន្ធរបស់នាយកដ្ឋានសោធនអតីតយុទ្ធជន នាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន មជ្ឈមណ្ឌលព្យាបាលដោយចលនា និងមន្ទីរកិច្ចការនារី និងអតីតយុទ្ធជនខេត្ត-ក្រុង ដែលសំរាប់ប្រើប្រាស់ក្នុងការងារវិស័យ អតីតយុទ្ធជន នៃអតីតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន អោយមកស្ថិតនៅក្រោមការ គ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**មាត្រា៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ និងអភិបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៤

**ហ៊ុន សែន**

**ចំលងជូនៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាទូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសម្តេច **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសម្តេចក្រុមព្រះ **នរោត្តម រណឬទ្ធិ** ជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល និងជាសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រ កម្ពុជា
- យោងអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អនុលោមតាមតំរូវការចាំបាច់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សំរេច

**មាត្រា ១** : បន្ថែមសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល ជាសហប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

មាត្រា១ នៃអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ត្រូវអានថា :

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហៅកាត់ថា "ក.អ.ក" ដែលមានសមាសភាពដូចតទៅ :

១- សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា សហប្រធាន

២- សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល សហប្រធាន

**មាត្រា ២** : កែសំរួលនិងបន្ថែមសមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមលេខរៀងបន្តបន្ទាប់ ក្នុងមាត្រា១ដដែល នៃ អនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ត្រង់ចំណុច រដ្ឋមន្ត្រីក្រសួងសង្គម កិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឬតំណាង និងរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីត យុទ្ធជន ឬតំណាង ដោយអានថា :

- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬតំណាង
- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតំណាង
- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឬតំណាង

**មាត្រា ៣** : បន្ថែមក្នុងមាត្រា៥ នៃអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ នូវលេខរៀងទី :

៩ - **ផ្នែកត្រួតពិនិត្យ និងតាមដានគំរោងវិនិយោគ។**

**មាត្រា ៤** : ក្រៅពីនេះ ខ្លឹមសារនៃអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ និងអនុក្រឹត្យ ១១២ អនក្រ.បក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២ នៅរក្សាទុកជាធរមានដដែល ។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធនឹងអនុក្រឹត្យនេះ ត្រូវអនុវត្តអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គាត ឈន់**

ចំលងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ៤៤៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយ ប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និង រៀបចំតំបន់អង្គរហៅថា អាជ្ញាធរអប្សរា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែ មករា ឆ្នាំ១៩៩៩ស្តីពីការកែសំរួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរអប្សរាដើម្បីការពាររមណីយដ្ឋាន និង រៀបចំតំបន់អង្គរហៅថា អាជ្ញាធរអប្សរា
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំនិងការប្រព្រឹត្ត ទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ស ម្រេ ច

**មាត្រា១** .-

ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០២ រូប ទៅអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរាដូចតទៅៈ

១-លោក **តាន់ ប៊ុនស៊ុយ** ជាប្រធាននាយកដ្ឋាន ប្រជាសាស្ត្រ និង ការអភិវឌ្ឍន៍

២-លោក **ហង់ តៅ** ជាប្រធាននាយកដ្ឋាន ទឹក និង ព្រៃឈើ

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកនៃអាជ្ញាធរអប្សរា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី-រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ សីហា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៥៧ អនក្រ.ត

# អនុក្រឹត្យ
## ស្តីពីការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម ដើម្បីធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រី រាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១.-**

ត្រូវបានដាក់ឱ្យលោក ង៉ែត ទិន ឋានន្តរស័ក្តិ វរៈមន្ត្រីថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងពាណិជ្ជកម្ម ចូលនិវត្តន៍ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៤
នាយករដ្ឋមន្ត្រី
ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ :..៤៥៧..ចា.ត

# អនុក្រឹត្យ
## ស្តីពីការតែងតាំង និង ផ្ទេរភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ១២៦ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតនាយកដ្ឋានស្ថិតិ និងពត៌មានចំណុះអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំង និងផ្ទេរភារកិច្ច មន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្ម ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១- តែងតាំងលោក | **សុខ សុគន្ធ** | បច្ចុប្បន្នប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ<br>ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស |
| ២- តែងតាំងលោក | **ឈី ផាណ្ណា** | បច្ចុប្បន្នប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា<br>ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស |
| ៣- ផ្ទេរភារកិច្ចលោក | **សង សម្បត្តិ** | បច្ចុប្បន្នអគ្គាធិការរង<br>ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស |
| ៤- តែងតាំងលោកស្រី | **ខៀវ សារ៉ាត** | បច្ចុប្បន្នប្រធាននាយកដ្ឋាន<br>ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៥- តែងតាំងលោក | **ចិន ឈ៉ាណ្ណា** | បច្ចុប្បន្នអធិការ<br>ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |

| | | | |
|---|---|---|---|
| ៦- | តែងតាំងលោក | **ឃី គឹមសេង** | បច្ចុប្បន្នប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស<br>ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន |
| ៧- | តែងតាំងលោក | **សួស វឌ្ឍនា** | បច្ចុប្បន្នប្រធាននាយកដ្ឋានបុគ្គលិក<br>ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន |
| ៨- | ផ្ទេរភារកិច្ចលោក | **អ៊ុយ សុខារ៉ាត្ន** | បច្ចុប្បន្នប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស<br>ឱ្យទៅជាប្រធាននាយកដ្ឋានស្ថិតិ និងពត៌មាន |
| ៩- | ផ្ទេរភារកិច្ចលោក | **ទ្រាក់ ឧក** | បច្ចុប្បន្នប្រធាននាយកដ្ឋានជំរុញការនាំចេញ<br>ឱ្យទៅជាប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស |
| ១០- | ផ្ទេរភារកិច្ចលោក | **ស៊ិត តារា** | បច្ចុប្បន្នប្រធាននាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ<br>ឱ្យទៅជាប្រធាននាយកដ្ឋានជំរុញការនាំចេញ |
| ១១- | ផ្ទេរភារកិច្ចលោក | **ម៉ក់ ពេជ្ររិទ្ធ** | បច្ចុប្បន្នប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម<br>ឱ្យទៅជាប្រធាននាយកដ្ឋាន កម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ |
| ១២- | តែងតាំងលោក | **ស៊ាង ថៃ** | បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ<br>ជាប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ |
| ១៣- | តែងតាំងលោក | **ទ៉ា រតនសាន** | បច្ចុប្បន្នអនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា<br>ជាប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា |
| ១៤- | តែងតាំងលោក | **ជួន ចន** | បច្ចុប្បន្នអនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស<br>ជាប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស |
| ១៥- | តែងតាំងលោក | **មាន សុភា** | បច្ចុប្បន្នអនុប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម<br>ជាប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| ១៦- | តែងតាំងលោក | **ឃឹម សិរីវឌ្ឍ** | បច្ចុប្បន្នអនុប្រធាននាយកដ្ឋានបុគ្គលិក<br>ជាប្រធាននាយកដ្ឋានបុគ្គលិក |

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០[illegible] ខែ សីហា ឆ្នាំ ២០០៤

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ ✓

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៥៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

តែងតាំងជាជំនួយការ ពិធីការ និងសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១- លោក | **សំ ចន្ណារ៉ា** | ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី | មានឋានៈស្មើ អគ្គនាយករង |
| ២- លោក | **ប៊ុន ខេង** | ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី | មានឋានៈស្មើ អគ្គនាយករង |
| ៣- លោកស្រី | **សេ់ ចំនួនល្វី** | ជាពិធីការសម្តេចនាយករដ្ឋមន្ត្រី | មានឋានៈស្មើ អគ្គនាយករង |
| ៤- លោក | **សុខ សុរិយា** | ជាពិធីការសម្តេចនាយករដ្ឋមន្ត្រី | មានឋានៈស្មើ អគ្គនាយករង |
| ៥- លោក | **ជា សានធឿន** | ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី | មានឋានៈស្មើ អគ្គនាយករង |
| ៦- លោក | **ខួន សំណាង** | ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី | មានឋានៈស្មើ អគ្គនាយករង |
| ៧- កញ្ញា | **ឈរ ស្រីតិង** | ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី | មានឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៨- លោក | **អ៊ុក ចន** | ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី | មានឋានៈស្មើ ប្រធាននាយកដ្ឋាន |

៩- លោក **ឈួន គីមឆយ** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន

១០- លោកស្រី **ទ៊ាន់ ចរិយា** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន

១១- លោក **ជាម ផារី** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន

១២- លោកស្រី **គង់ ម៉ារីយ៉** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន

១៣- លោកស្រី **ញ៉ែម ស៊ុណនាត** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន

១៤- លោកស្រី **មាស វិចិត្រ** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន

១៥- លោកស្រី **ឆេង សុផារី** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន

១៦- លោកស្រី **ច័ក់សម័យ សុវិឡាន** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន

១៧- លោក **ឆេង ស៊ុថា** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន

១៨- លោក **មាស វិបុល** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន

១៩- លោក **សុខ វីរៈ** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន

២០- លោក **ឈន ម៉េងឡេង** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន

២១- លោក **នី ប៊ុនលី** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន

២២- លោក **លី ត្រាណលិន** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន

**មាត្រា ២**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល :**

ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៥៩ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោកវរៈសេនីយ៍ទោ ចាន់ ប្រកប អត្តលេខ ០៤៥២ ។

២-លោកវរៈសេនីយ៍ទោ **ឡឿង** ប៊ុនធី អត្តលេខ ០៤៥៣ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៨ ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៦០.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

របស់

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាឱ្យដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា ១.** -

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោក **ឌី សុផល** ជំនួយការផ្ទាល់ ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេច **ជា ស៊ីម** និង ជាប្រធានអនុវត្តគំរោងអភិវឌ្ឍន៍ ស្រែអំពិល ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ជួយស្តារ និង អភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម ជនបទ រួមចំណែកកាត់បន្ថយភាពក្រីក្រ ជូនប្រជាពលរដ្ឋ ។

**មាត្រា ២.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ៧ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧៦២ សហវ.ប្រក

ភ្នំពេញថ្ងៃទី០៣ខែ សីហា ឆ្នាំ២០០៤

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការតាមដានការអនុវត្តន៍ថវិកា និង គ្រប់គ្រងសាច់ប្រាក់

**** + ****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ-បង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-យោងប្រកាសលេខ ២១៨ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

-យោងសំណូមពរចាំបាច់នៃការងារកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ

## សម្រេច

*****

ប្រការ ១: បង្កើតគណៈកម្មការតាមដានការអនុវត្តន៍ថវិកា និង គ្រប់គ្រងសាច់ប្រាក់ ហៅកាត់ថា «គថស» (Budget Monitoring and Cash Management Commission "BMC") នៅក្រោមគណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរួមមានសមាសភាពដូចខាងក្រោម ÷

*I. ថ្នាក់ដឹកនាំ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (កសហវ)*

| | | |
|---|---|---|
| ១ - ឯកឧត្តម **គួន ពាំងមុនីរ័ត្ន** | រដ្ឋលេខាធិការ កសហវ | ប្រធាន |

*II. ថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន កសហវ*

| | | |
|---|---|---|
| ២ - ឯកឧត្តម **ហង់ ជួន ណារ៉ុន** | អគ្គលេខាធិការ កសហវ | អនុប្រធាន |
| ៣ - ឯកឧត្តម **ជុំ គឹមឡេង** | អគ្គលេខាធិការរង កសហវ | អនុប្រធានប្រចាំការ |
| ៤ - ឯកឧត្តម **ទន្សី វិសុទ្ធ** | អគ្គលេខាធិការរង កសហវ | សមាជិក |
| ៥ - ឯកឧត្តម **ជុំ វិជិត្ត** | អគ្គលេខាធិការរង កសហវ | សមាជិក |
| ៦ - ឯកឧត្តម **ហ៊ាន សាហ៊ីប** | អគ្គលេខាធិការរង កសហវ | សមាជិក |

*III. ថ្នាក់ដឹកនាំនាយកដ្ឋាន កសហវ*

| | | |
|---|---|---|
| ៧ - ឯកឧត្តម **ម៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ទីចាត់ការគយ និង រដ្ឋាករ | សមាជិក |
| ៨ - ឯកឧត្តម **ទិន យន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធាន រតនាគារជាតិ | សមាជិក |
| ៩ - លោក **នួច ឡេង** | ប្រធាននាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច | សមាជិក |
| ១០ - លោក **យិនឌី តាំយឈង់** | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១ - លោក **មិម និច** | អគ្គាធិការ | សមាជិក |
| ១២ - លោក **ហុង ថា** | ប្រធាននាយកដ្ឋានពន្ធដារ | សមាជិក |
| ១៣ - លោក **ចាន់ សុធី** | ប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ | សមាជិក |
| ១៤ - លោក **ភាំង លាងខ័ណ្ឌ** | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១៥ - លោក **លីវ ម៉ិនហៃ** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន | សមាជិក |
| ១៦ - លោក **ឆាយ ទុង** | ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ១៧ - លោក **ជា ទុងណា** | ប្រធាននាយកដ្ឋានវិភាគ និង ព្យាករណ៍សេដ្ឋកិច្ច | សមាជិក |
| ១៨ - លោក **ម៉ី ទាំង** | ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ១៩ - លោក **ឃុត សាខន** | ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ ២:** «គជស» មានភារកិច្ចដូចតទៅ ÷

*I. នៅក្នុងការរៀបចំគោលនយោបាយ និង ត្រួតពិនិត្យការអនុវត្តន៍ថវិកា :*

- ដើរតួជាអ្នកសំរបសំរួលជាមួយនាយកដ្ឋាន និង សមត្ថកិច្ចទាំងឡាយនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលទទួលខុសត្រូវលើការរៀបចំ និង កិច្ចប្រតិបត្តិការថវិកាទូទាំងខ្ទប ។
- ផ្តល់នូវសេចក្តីណែនាំសម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំ រួមមានជាអាទិ៍ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ក្របខ័ណ្ឌគោលនយោបាយថវិកាសម្រាប់គ្រប់គ្រងឆ្នាំ និង សេចក្តីព្រាងសារាចរណែនាំស្តីពី ការរៀបចំថវិកាប្រចាំឆ្នាំ ដើម្បីដាក់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យសម្រេច ។
- តាមដាន និង ត្រួតពិនិត្យដោយប្រុងប្រយត្ន័ លើការអនុវត្តន៍សេចក្តីណែនាំនានា ពាក់ព័ន្ធនឹង ការរៀបចំ និង អនុវត្តថវិកា ។
- ពិនិត្យ និង ផ្តល់សេចក្តីណែនាំលើការរៀបចំសេចក្តីព្រាងច្បាប់សំរាប់ការគ្រប់គ្រងថវិកាប្រចាំ ឆ្នាំ ដែលរៀបចំឡើងដោយនាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច ដោយមានការជួយជ្រោម ជ្រែងពីនាយកដ្ឋាននីតិកម្ម សម្រាប់ជូនទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យ និង សម្រេច រួចហើយដាក់សុំការអនុម័តពីគណៈរដ្ឋមន្ត្រី និង ស្ថាប័ននីតិបញ្ញត្តិ ។
- ពិនិត្យ និង អនុមត៌លើកម្មវិធីលម្អិត សម្រាប់ការរៀបចំផែនការអនុវត្តថវិកា រួមមានការណែនាំ អនុវត្តថវិការបស់ កសហវ សម្រាប់ជូនដល់ក្រសួង- ស្ថាប័ននានា ការរៀបចំកម្មវិធីថវិកា ប្រចាំត្រីមាស ហើយតាមដាន និង ត្រួតពិនិត្យឡើងវិញ ជាប្រចាំ នូវការអនុវត្តន៍កម្មវិធី និង ការណែនាំទាំងអស់នេះ ។
- ផ្តល់សេចក្តីណែនាំ និង រៀបចំដាក់ឱ្យអនុវត្តនូវទម្រង់លម្អិតនៃការព្យាករណ៍រំកិលប្រចាំខែ នៃ របាយការណ៍អំពីរាល់ចំណូល និង ប្រភពថវិកាដ៏ទៃទៀត និង អំពីចំណាយទាំងអស់នៃថវិកា ជាតិ ។
- ផ្តល់ការណែនាំដល់នាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច និង រតនាគារជាតិ ព្រមទាំង នាយកដ្ឋានពាក់ពន្ធ័ដទៃទៀត ដើម្បីអភិវឌ្ឍផែនការអនុវត្តថវិកា ហើយនៅក្នុងដំណាក់កាល អនុវត្តផែនការនេះ ធ្វើការតាមដាន ត្រួតពិនិត្យ និង កែតម្រូវ ទៅតាមតម្រូវការចាំបាច់ លើ ផែនការនេះ ដោយសហការយ៉ាងជិតស្និទជាមួយនឹងក្រសួង- ស្ថាប័នចំណាយ និងនាយកដ្ឋាន ពាក់ព័ន្ធនៃ កសហវ សំដៅធានាឱ្យបាននូវតុល្យភាពរួមរបស់ថវិកាជាតិ ភាពគត់មត់ក្នុងការ- គ្រប់គ្រងការធានាចំណាយកុំឱ្យលើសឥណទានដែលបានអនុម័ត និង ភាពផ្សារភ្ជាប់គ្នារវាង សំណើបន្ថែមឥណទានថវិកា ជាមួយនឹងប្រភពហិរញ្ញប្បទាន និង រវាងការបោះផ្សាយអាណត្តិ ទូទាត់ ជាមួយនឹងសមត្ថភាពបើកផ្តល់សាច់ប្រាក់របស់រតនាគារជាតិ ។
- ដឹកនាំការងារត្រួតពិនិត្យឡើងវិញប្រចាំឆមាស លើការអនុវត្តន៍ថវិកា ដោយផ្អែកលើសភាព- ការណ៍ជាក់ស្តែងនៃម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈនៅក្នុងប្រទេស ហើយក្នុងករណី ចាំបាច់ស្នើឡើងនូវវិធានការកែតម្រូវការអនុវត្តន៍ថវិកា ដែលរួមមានទាំងការផ្តល់អនុសាសន៍ លើភាពចាំបាច់ក្នុងការរៀបចំច្បាប់កែតម្រូវការគ្រប់គ្រងថវិកាប្រចាំឆ្នាំផងដែរ ។

*II. នៅក្នុងការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ :*

- រៀបចំបង្កើត និង គ្រប់គ្រងឱ្យបានល្អិតល្អន់ នូវយន្តការវិភាជន៍សាច់ប្រាក់ សម្រាប់ចំណាយថវិកា ក្នុងរយៈពេលចំពោះមុខ និង ក្នុងក្របខ័ណ្ឌរយៈពេលមធ្យម ដោយឈរលើមូលដ្ឋានរឹងមាំនៃការព្យាករណ៍ចំណូលដ៏ត្រឹមត្រូវ ។
- ស្នើឡើងនូវវិភាជន៍ចំណាយថវិកាប្រចាំឆ្នាំ និងរយៈពេលមធ្យម ដើម្បីជម្រះបំណុលសាច់ប្រាក់ជាយថាហេតុ ។
- ធានាគ្រប់គ្រងចំណាយឱ្យស្ថិតនៅក្នុងកម្រិតមួយ ដែលធនាគារជាតិអាចមានសមត្ថភាពទូទាត់បាន ហើយពិនិត្យតាមដាន និង វាយតម្លៃជាប់ជាប្រចាំលើស្ថានភាពបច្ចុប្បន្ន និង អនាគត នៃលំហូរសាច់ប្រាក់ សមតុល្យ និង សាច់ប្រាក់បម្រុង នៅកំឡុងពេលអនុវត្តន៍ថវិកា ។
- ផ្តល់ការណែនាំតាមតម្រូវការចាំបាច់ ដល់នាយកដ្ឋាន និង អង្គភាពដែលមានការពាក់ព័ន្ធក្នុងការអនុវត្តន៍កិច្ចដំណើរការប្រមូលផ្តុំ និង ធ្វើសមាហរណកម្មគណនីរបស់រាជរដ្ឋាភិបាលទាំងអស់ ហើយធានានូវការគ្រប់គ្រងគណនីទាំងអស់នេះ ប្រកបដោយប្រសិទ្ធភាព ដោយសហការយ៉ាងជិតស្និទជាមួយធនាគារជាតិនៃកម្ពុជា ។
- តាមដានជាប្រចាំអំពីស្ថានភាពសាច់ប្រាក់របស់រដ្ឋ ហើយស្នើឡើងនូវវិធានការកាត់បន្ថយការ-រក្សាសាច់ប្រាក់ទំនេរឥតប្រយោជន៍ នៅតាមគណនីនានា រួមទាំងនៅតាមបេឡាធនាគារខេត្ត-ក្រុងផង ឱ្យស្ថិតនៅក្នុងកម្រិតអប្បបរមា ដើម្បីធានាបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់សាច់-ប្រាក់របស់រដ្ឋ ។
- រៀបចំ និង តាមដានត្រួតពិនិត្យការអនុវត្តន៍កម្មវិធីបើកផ្តល់សាច់ប្រាក់សម្រាប់ចំណាយអាទិ-ភាពទាំងឡាយរបស់រដ្ឋ ពិសេសកម្មវិធីសកម្មភាពអាទិភាព (PAP) និង សម្រាប់ចំណាយផ្សេងទៀត ដែលមានវេទយិតភាព រួមមានប្រាក់បុរេប្រទានបន្ទាន់ និង ការសងបំណុលសាច់ប្រាក់កកស្ទះរបស់ក្រុមហ៊ុននានាផងដែរ ។
- ផ្តល់ការណែនាំផ្សព្វផ្សាយជូនចំពោះនាយកដ្ឋានទាំងឡាយ ស្របតាមការសម្រេចចិត្តរបស់ថ្នាក់លើ និង របស់ខ្លួនផ្ទាល់ ស្តីពីសកម្មភាពចាំបាច់នានាក្នុងការ :
    - ធ្វើផែនការសាច់ប្រាក់ឱ្យបានទាំងស្រុង និង មានចិរភាព សម្រាប់អនុវត្តថវិកា តាមក្រសួង- ស្ថាប័នទាំងអស់ ជាមួយនាយកដ្ឋានពាក់ព័ន្ធរបស់ គសហវ និង ដោយកំណត់កម្រិតពិដាននៃការធានាចំណាយ ឱ្យគ្រប់ប្រភេទឥណទានទាំងអស់ក្នុងមួយខែម្តង ។
    - ត្រួតពិនិត្យអត្រាធានាចំណាយ ឱ្យស្របតាមកម្រិតពិដានដែលបានអនុម័តប្រចាំខែ ។
    - គ្រប់គ្រង និងតាមដានចំណូល- ចំណាយថវិកា ព្រមទាំងអន្តរកម្មនៃសាច់ប្រាក់ ហើយក្នុងនេះ «គថស» ត្រូវប្រកាសជាបន្ទាន់ ប្រសិនបើពិនិត្យឃើញមានសញ្ញាឃ្លាតចេញពីផែនការទាំងនោះ ដោយនូវផ្តល់អនុសាសន៍ឱ្យមានវិធានការកែតម្រូវ រួមមានទាំង

វិធានការកាត់បន្ថយឥណទានថវិកាផង កាលណាការគ្រប់គ្រងចំណាយរបស់ក្រសួង-ស្ថាប័នណាមួយបង្ហាញឃើញថា នឹងអាចនាំឱ្យមានផលប៉ះពាល់អាក្រក់ដល់តុល្យ-ភាពរួមនៃថវិកាជាតិ ។

- ក្នុងករណីមានការវិនាទដល់តុល្យភាពថវិកា ដោយសារតែចំណុចខ្សោយនៃប្រព័ន្ធថវិកាដែលនាំឱ្យខ្វះខាតសាច់ប្រាក់ «គជស» ត្រូវផ្តល់មតិយោបល់ជូនទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ ស្តីពីការរៀបចំជាអាទិភាពបើកផ្តល់សាច់ប្រាក់ចំពោះអាណត្តិដែលបានបោះផ្សាយហើយ និង ការ-កំណត់អាទិភាពក្នុងការបោះផ្សាយអាណត្តិបន្តទៀត ហើយស្នើឡើងនូវយុទ្ធសាស្ត្រស្តារតុល្យភាពថវិកាឡើងវិញ ឱ្យបានឆាប់រហ័ស តាមការដែលអាចធ្វើទៅបាន ដោយជូនជាជម្រើសដើម្បីបង្កកឥណទានមួយចំនួន និង បញ្ជាក់អំពីផលប៉ះពាល់នៃការបង្កកនេះ ដែលអាចកើតមានឡើងចំពោះការអនុវត្តន៍គោលនយោបាយ កម្មវិធី និង សេវាទាំងឡាយរបស់រដ្ឋ ។

ប្រការ ៣: «គជស» ធ្វើការប្រជុំសាមញ្ញរបស់ខ្លួនក្នុងមួយខែមួយដង តាមការអញ្ជើញរបស់ប្រធាន ឬ អាចប្រជុំញឹកញាប់ជាងនេះ ទៅតាមតម្រូវការចាំបាច់នៃការងារ ។

ប្រការ ៤: ប្រធាន «គជស» អាចអញ្ជើញថ្នាក់ដឹកនាំ ប្រធាននាយកដ្ឋាន និង មន្ត្រីជំនាញនានានៃ កសហវ ដែលមិនមែនជាសមាជិកនៃ «គជស» ឱ្យចូលរួមប្រជុំ ទៅតាមតម្រូវការចាំបាច់នៃការងារ ។

ប្រការ ៥: ក្នុងករណីអវត្តមាន សមាជិកនៃ «គជស» ដែលជាប្រធាននាយកដ្ឋាន អាចស្នើសុំការអនុញ្ញាតពីប្រធាន ដើម្បីចាត់តាំងអនុប្រធាននាយកដ្ឋានមួយរូប ឱ្យចូលរួមប្រជុំជំនួស ។ សមាជិក «គជស» អាចស្នើសុំការអនុញ្ញាតពីប្រធាន ឱ្យមន្ត្រីជំនាញដែលមានការពាក់ព័ន្ធ ចូលរួមប្រជុំក្នុងឋានៈជាមន្ត្រីជំនួយការ ។

ប្រការ ៦: «គជស» មានអនុគណៈកម្មការចំនួន ២ សម្រាប់ជួយការងាររបស់ខ្លួន គឺ :

- អនុគណៈកម្មការគ្រប់គ្រងសាច់ប្រាក់ និង
- អនុគណៈកម្មការគ្រប់គ្រងចំណូល- ចំណាយ ។

ប្រការ ៧: អនុគណៈកម្មការគ្រប់គ្រងសាច់ប្រាក់ រួមមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **ចិន ឃន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានធនាគារជាតិ ប្រធាន
២- លោក **ហ៊ីទ សុទណ្ណ** អនុប្រធានទី ១ ធនាគារជាតិ អនុប្រធាន
៣- លោក **ឈឹម សារ៉េត** អនុប្រធានធនាគារជាតិ សមាជិក
៤- លោក **គុណ ញឹម** នាយករងទី ១ នៃទីចាត់ការពន្ធ និង រដ្ឋាករ សមាជិក
៥- លោក **ប៊ី ចន្ទសុខា** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន សមាជិក

៦- លោក ឃុ តិរម្យ អនុប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ សមាជិក

៧- លោក ទ៊ុន សុមេធ អនុប្រធាននាយកដ្ឋានវិភាគ និង ព្យាករណ៍សេដ្ឋកិច្ច សមាជិក

៨- លោក ឈាន ហឿន ប្រធានការិយាល័យស្រាវជ្រាវធនាគារជាតិ សមាជិក

៩- លោក ស៊ាន ម៉ារឡូត ប្រធានអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ សមាជិក

១០- លោក ចៅ យុទ្ធថា ប្រធានការិយាល័យសហប្រតិបត្តិការទ្វេរភាគី សមាជិក

១១- លោកស្រី ស៊ិន ណារី ប្រធានការិយាល័យគ្រប់គ្រងបំណុល សមាជិកា

១២- លោក ស៊ិនណារុយ ប្រធានការិយាល័យគ្រប់គ្រងថវិកាសាលាខេត្ត- ក្រុង សមាជិក

ប្រការ ៨: អនុគណៈកម្មការគ្រប់គ្រងសាច់ប្រាក់មានភារកិច្ចដូចតទៅ ÷

- ធ្វើការប្រជុំទៀតទាត់ ដើម្បីពិនិត្យស្ថានភាពសាច់ប្រាក់ពិតប្រាកដរបស់រដ្ឋដោយផ្អែកលើស្ថាន- ភាពសមតុល្យបេឡានៅរតនាគារជាតិ និង នៅធនាគារ រួមទាំងគណនីចំណូលថវិការដូនៅធនាគារជាតិនៃកម្ពុជា ដែលអាចធ្វើហិរញ្ញប្បទានឱ្យចំណាយរបស់រដ្ឋ ។
- តាមដានការគ្រប់គ្រងសាច់ប្រាក់ប្រចាំថ្ងៃ ដើម្បីធានាលំហូរចូលនៃសាច់ប្រាក់សម្រាប់ទូទាត់ចំណាយរបស់រដ្ឋ (អាណត្តិបោះផ្សាយ ហើយបានបញ្ជូនទៅដល់រតនាគារ និង បុរេប្រទានសាច់ប្រាក់ដែល កសហវ បានសម្រេច) ។ ប្រសិនបើលំហូរចូលនៃសាច់ប្រាក់ក្នុងគណនីមិនមានគ្រប់គ្រាន់សម្រាប់ទូទាត់ចំណាយ អនុគណៈកម្មការគ្រប់គ្រងសាច់ប្រាក់ ត្រូវលើកវិធានការទូទាត់ចំណាយតាមលំដាប់អាទិភាព ស្របតាមកាតព្វកិច្ចថវិកា និង តាមការណែនាំរបស់ កសហវ ។
- កំណត់តម្រូវការហិរញ្ញប្បទានប្រចាំថ្ងៃសម្រាប់ចំណាយរបស់រដ្ឋនៅរដ្ឋបាលកណ្តាល ព្រមទាំងតម្រូវការហិរញ្ញប្បទានប្រចាំខែសំរាប់ចំណាយសេវារបស់រដ្ឋ និង សេវារបស់អភិបាលខេត្តក្រុង និង ក្រុមប្រឹក្សាឃុំ- សង្កាត់ ។ ក្នុងនេះ អនុគណៈកម្មការគ្រប់គ្រងសាច់ប្រាក់ត្រូវរៀបចំ :
  - ស្ថានភាពសាច់ប្រាក់ប្រចាំថ្ងៃ សម្រាប់រដ្ឋបាលកណ្តាល និង ប្រចាំខែ សម្រាប់សេវាខេត្ត- ក្រុង និង ឃុំ- សង្កាត់ ដើម្បីទូទាត់ចំណាយរបស់រដ្ឋ ដោយផ្អែកលើស្ថានភាពសាច់ប្រាក់នៅបេឡារតនាគារ និង នៅធនាគារ ។
  - ស្ថានភាពលំហូរចេញ- ចូលនៃសាច់ប្រាក់ ដែលបានអនុវត្តជាក់ស្តែងក្នុងខែស្របតាមប្រតិបត្តិការថវិកា ។

ប្រការ ៩: អនុគណៈកម្មការគ្រប់គ្រងចំណូល- ចំណាយថវិកា រួមមានសមាសភាព ដូចខាងក្រោម :

១- ឯកឧត្តម ជុំ គីមឡេង អគ្គលេខាធិការរង ប្រធាន

២- លោក នួច ឡេង ប្រធាននាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច អនុប្រធាន

៣- លោក ចាន់ សុធី ប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ សមាជិក

៤- លោក **ហុង ថា** ប្រធាននាយកដ្ឋានពន្ធដារ សមាជិក

៥- លោក **គាំង សាខវ័ណ្ណ** ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ សមាជិក

៦- លោក **លីម ម៉ិនហៃ** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន សមាជិក

៧- លោក **អៀងស៊ុនលី** អនុប្រធានទី ១ នាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច សមាជិក

៨- លោក **នេត មុន្នី** អនុប្រធានទី ១ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ សមាជិក

៩- លោក **សៀង ឈុនឡី** នាយករងទីចាត់ការគយ និង រដ្ឋាករ សមាជិក

១០- លោក **ម៉ម ប៊ុន** អនុប្រធាននាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច សមាជិក

១១- លោក **ម៉ុង ស៊ុម** អនុប្រធាននាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច សមាជិក

១២- លោក **រស់ ចរម** អនុប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ សមាជិក

១៣- លោក **កែវ បេងឡន់** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន សមាជិក

១៤- លោក **ជា មិន** ប្រធានការិយាល័យគ្រប់គ្រងការងារហិរញ្ញកិច្ច សមាជិក

១៥- លោក **ឆា សេ** ប្រធានការិយាល័យគ្រប់គ្រងថវិការដ្ឋបាលកណ្តាល សមាជិក

ប្រការ ១០: អនុគណៈកម្មការគ្រប់គ្រងចំណូល- ចំណាយ មានភារកិច្ចដូចតទៅ :

- ធ្វើការប្រជុំទៀងទាត់ ដើម្បីពិនិត្យស្ថានភាពចំណូល- ចំណាយថវិកា តាមដានការសន្យាចំណាយ ការបោះផ្សាយអាណត្តិ ការធ្វើបុរេប្រទាន និង ការទូទាត់ប្រាក់បុរេប្រទាន ។

- ប្រសិនបើមានអាណត្តិកកស្ទះនៅរតនាគារជាតិ ដោយសារមូលហេតុលំហូរសាច់ប្រាក់ចូលក្នុងគណនីមិនគ្រប់គ្រាន់សម្រាប់ទូទាត់ចំណាយ អនុគណៈកម្មការគ្រប់គ្រងចំណូល- ចំណាយ ត្រូវស្នើវិធានការផ្អាកការបោះផ្សាយអាណត្តិដែលធ្វើឡើងដោយអាណាប័ក បន្ថយការសន្យាចំណាយ និង លើកវិធានការប្រមូលសាច់ប្រាក់ តាមរយៈការជម្រុញបង់ចំណូល ជូន «**គវស**» ដើម្បីដាក់ជូនទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គសហវ ពិនិត្យ និង សំរេច ។

ប្រការ ១១: «**គវស**» អាចបង្កើតក្រុមការងារផ្សេងទៀត ដើម្បីជួយការងាររបស់ខ្លួន តាមតម្រូវការចាំបាច់ ។

ប្រការ ១២: «**គវស**» មានលេខាធិការដ្ឋានសម្រាប់ជាជំនួយការរួមរបស់ខ្លួន ដែលមានសមាសភាពដូចខាងក្រោម :

១- លោក **ឈឹម សារ៉េត** អនុប្រធានរតនាគារជាតិ ប្រធាន

២- លោក **ស៊ាន ម៉ាឡូត** ប្រធានអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ អនុប្រធាន

៣- លោក **ជា មិន** ប្រធានការិយាល័យគ្រប់គ្រងការងារហិរញ្ញកិច្ច អនុប្រធាន

៤- លោក **ស៊ិន ណុយ** ប្រធានការិយាល័យគ្រប់គ្រងថវិកាសាលាខេត្ត- ក្រុង សមាជិក

៥- លោក **ឆា សេ** ប្រធានការិយាល័យគ្រប់គ្រងថវិការដ្ឋបាលកណ្តាល សមាជិក

៦- លោក **ខៀវ ខេមរជាតិ** អនុប្រធានការិយាល័យចំណូលថវិកាជាតិ សមាជិក

៧- លោកស្រី **នីវ សុចិន្តា** អនុប្រធានអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ សមាជិកា

៨- លោក **ស៊ិន ហេង** អនុប្រធានការិយាល័យនៃនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ សមាជិក

៩- លោកស្រី **កែវ ផល្លី** មន្ត្រីការិយាល័យគ្រប់គ្រងថវិការដ្ឋបាលកណ្ដាល សមាជិកា

១០- លោកស្រី **ហួយ ហេង** មន្ត្រីអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ សមាជិកា ។

ប្រការ ១៣: លេខាធិការដ្ឋាន «**គជស**» មានភារកិច្ច ដូចតទៅ :

- ផ្ដល់ការគាំទ្រផ្នែករដ្ឋបាល និង បច្ចេកទេស ជូនដល់ «**គជស**» និង អនុគណៈកម្មការផ្សេងៗ របស់ «**គជស**» ។
- ធ្វើជាលេខាធិការរបស់ «**គជស**» ក្នុងការតាមដាន និង បូកសរុបការងារ របស់អនុគណៈ-កម្មការ និង ក្រុមការងារទាំងឡាយ ដែលស្ថិតនៅក្រោមឱវាទ «**គជស**» ។
- បំពេញតួនាទីជាចំណុចប្រមូលផ្ដុំរបស់ «**គជស**» ក្នុងការសម្របសម្រួលរាល់ការងារដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ «**គជស**» តាមការណែនាំរបស់ប្រធាន «**គជស**» ។
- បំពេញការងារផ្សេងទៀត ដែលប្រធាន «**គជស**» ប្រគល់ជូន ។

ប្រការ ១៤: រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ និង ប្រកាសលេខ ៦១៩ សហវ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៣ ត្រូវទុកជានិរាករណ៍ ។

ប្រការ ១៥: អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក គ្រប់ប្រធាននាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចប្រការ ១ ប្រការ ៧ ប្រការ ៩ និង ប្រការ ១២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

<u>ចម្លងជូន:</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង- ស្ថាប័ន និង ខេត្ត- ក្រុង
- គ្រប់ថ្នាក់ដឹកនាំនៃ កសហវ
- គ្រប់នាយកដ្ឋានក្រោមឱវាទ កសហវ
- សាមីខ្លួន ដើម្បីអនុវត្ត
- កាលប្បវត្តិ- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ៩៦០ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពី

## ការទប់ស្កាត់សកម្មភាពឆ្នាំឆ្លង ដែលប៉ះពាល់ដល់ព្រះពុទ្ធសាសនា

## ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ៥៤អនក្រ-បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតំរូវការចាំបាច់ក្នុងការជួយថែរក្សា និង លើកកំពស់កិត្យានុភាពព្រះពុទ្ធសាសនា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## សំរេច

**ប្រការ១:** មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាចែងថា ព្រះពុទ្ធសាសនាជាសាសនា របស់រដ្ឋ។ មាត្រា ៤(ខ) នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិន ស្មោះត្រង់ ចែងថា ម៉ាកដែលពុំអាចចុះបញ្ជីបានគឺ ម៉ាកទាំងឡាយណាដែលប៉ះពាល់ដល់ សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ។ ដូច្នេះរាល់សកម្មទាំងឡាយ រួមទាំងសកម្មភាព ផ្នែកពាណិជ្ជកម្ម ផលិតកម្ម



Ministry of Commerce # 20 A & B Preah Norodom Boulevard. Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http //www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile (855-23) 426396

សេវាកម្ម និង សកម្មភាព សាធារណៈដ៏ទៃទៀត ដូចជាការសំដែងសិល្បៈរបាំ ប្រគុំដូរ្យតន្ត្រី ។ល។ ដែលធ្វើអោយ ប៉ះពាល់ ដល់ការគោរព បូជាចំពោះព្រះពុទ្ធសាសនា ត្រូវបានចាត់ទុកថា ជាសកម្មភាពមាក់ងាយ ដល់ព្រះពុទ្ធសាសនា និង ប៉ះពាល់ដល់ប្រពៃណីជាតិ ។

**ប្រការ២:** ដោយយោងតាមខ្លឹមសារនៃប្រការ ១ ខាងលើ រាល់ការនាំចូល ការផលិត ការតាំងលក់ និង ការផ្សព្វផ្សាយពាណិជ្ជកម្មតាមមធ្យោបាយផ្សេងៗ នូវផលិតផលជាសំភារៈប្រើប្រាស់ ផលិតផលតាំងលំអ រូបភាពឃោសនា ភេសជ្ជៈ គ្រឿងស្រវឹង ដែលប្រើរូបភាព និង រូបលំនាំ (Caricature) រូបថ្លុកពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា ជាពិសេសការនាំចូល ការផលិត ការតាំងលក់ ខោខ្លីសំរាប់មុជទឹករបស់នារី ទៀនសំរាប់អុជក្នុងករណីផ្សេងក្រៅពីការបូជាព្រះពុទ្ធសាសនា ស្រាបៀរ សុរា ដែលមានបោះពុម្ព រូបភាពព្រះពុទ្ធនៅពីលើ និង ថាសចំរៀងដែលមាន ឈ្មោះថា " **Buddha Bar** " ត្រូវបានហាមឃាត់ជាដាច់ខាត ។

**ប្រការ៣:** ទង្វើទាំងឡាយណារបស់ អាជីវករ ផលិតករ សេវាករ ដែលផ្ទុយទៅនឹងការណែនាំក្នុង ប្រការ ២ខាងលើ ត្រូវចាត់ទុកជាអំពើល្មើស ហើយនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និង បទប្បញ្ញត្តិ ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** នាយកដ្ឋានកាំកុងត្រូល និងនាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវសហការណ៍ជាមួយស្ថាប័នមានសមត្ថកិច្ច ដែលពាក់ព័ន្ធផ្សេងៗទៀត រាំងខ្ទប់នូវអំពើល្មើសទាំងឡាយ ដូចមានចែងក្នុងប្រការ២ នៅតាមមាត់ច្រកព្រំដែន និងនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា អោយ ទទួលបានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ៥:** ប្រកាសនេះចូលជាធរមាន ចាប់ពីពេលចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចំលងជូន</u>**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សោ ខេង**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងធម្មការ និង កិច្ចការសាសនា
- ទីចាត់ការគយ និង រដ្ឋករ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ